# ការសំភាសន៍របស់ម៉ាក់យាយ គឹម វណ្ណា

កះ  អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ាវ        ខះ  អ្នកដែរអោយគេសំភាសន៍ គឹម វណ្ណា

## <u>ការសង្ខេបប្រវត្តិរបស់ ម៉ាក់យាយ គឹម វណ្ណា</u>

ម៉ាក់យាយ គឹម វណ្ណា មានអាយុ65ឆ្នាំ នៅក្នុងឆ្នាំ2018 ម៉ាក់យាយ គឹម វណ្ណា មានភេទស្រីម៉ាក់យាយគឹម វណ្ណា មានទីលំនៅបច្ចុប្បន្ននៅភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ នៅរាជធានីភ្នំពេញ។

កះ  ចឹងជាដំបូងខ្ញុំអរគុណម៉ាក់យាយដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ម៉ាក់យាយ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយនឹង ប្រវត្តិរបស់ជូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍ម៉ាក់យាយ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់ម៉ាក់យាយយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេម៉ាក់យាយ?

ខះ  ចង់ដាក់យ៉ាងម៉េចដាក់ទៅក្មួយឯងខ្ញុំមិនដឹងទេ

កះ  បាទម៉ាក់យាយចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍ម៉ាក់យាយខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍ម៉ាក់យាយគឺនៅថ្ងៃទី22 ខែ3 ឆ្នាំ2018 ចឹងសំរាប់ភូមិនឹងគេហៅភូមិអីគេដែរម៉ាក់យាយ?

ខះ  នេះភូមិព្រែកតាគង់។

កះ  នៅភូមិព្រែកតានូហីម៉ាក់យាយ?

ខះ  ទេនៅភូមិព្រែកតាគង់។

កះ  ភូមិព្រែកតាគង់ហោសម៉ាក់យាយ ចុះឃុំអីគេដែរម៉ាក់យាយ?

ខ៖ ចាំ!!សង្កាត់ចាក់អង្រែលើ។

ក៖ សង្កាត់ចាក់អង្រែលើ?

ខ៖ ចាំ!!សង្កាត់ចាក់អង្រែលើ នៅភូមិព្រែកតាគង់នឹង។

ក៖ នៅខ័ណ្ឌមានជ័យមែនទេម៉ាក់យាយ?

ខ៖ ខ័ណ្ឌមានជ័យនឹង។

ក៖ ខ័ណ្ឌមានជ័យនឹង នៅរាជធានីភ្នំពេញ?

ខ៖ នឹងហើយ។

ក៖
បាទចឹងសំរាប់ម៉ាក់យាយឈ្មោះពេញរបស់ម៉ាក់យាយនឹងមានឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖ ខ្ញុំឈ្មោះគឹម វណ្ណា។

ក៖ ចុះមានឈ្មោះហៅក្រៅទេម៉ាក់យាយ?

ខ៖ អត់ទេចឹងហៅតែគឹម វណ្ណាចឹងតែម្តងនឹង។

ក៖ អូ៎!!ចុះកាលពីក្មេងនឹងមាននរណាហៅម៉ាក់យាយអីផ្សេងទេ?

ខ៖ អត់ទេនឹង។

ក៖ អត់ទេណាម៉ាក់យាយ ចុះសព្វថ្ងៃនឹងម៉ាក់យាយអាយុប៉ុន្មានដែរទៅម៉ាក់យាយ?

ខ៖ ខ្ញុំអាយុ65ឆ្នាំ។

ក៖ ចឹងម៉ាក់យាយអាយុ65ឆ្នាំណាម៉ាក់យាយ
ចុះម៉ាក់យាយមានចងចាំថ្ងៃខែឆ្នាំកំណើតរបស់ម៉ាក់យាយដែរទេ?

ខ៖ ខ្ញុំភ្លេចអស់ហើយនឹងខ្ញុំអត់ចងចាំទេ។

ក៖ អូ៎!!បាទម៉ាក់យាយ?

ខ៖ ខ្ញុំដឹងថាខ្ញុំឆ្នាំនេះនឹងខ្ញុំឆ្នាំម៉្សាញ់ហើយនឹងខ្ញុំអាយុ65ឆ្នាំនឹង។

កៈ ចុះប៉ុន្តែឆ្នាំម៉ាក់យាយអត់ចាំដែរ?

ខៈ ឆ្នាំម្សាញ់។

កៈ ប៉ុន្តែឆ្នាំប៉ុន្មានម៉ាក់យាយចងចាំទេ?

ខៈ អត់ចងចាំទេទាល់តែមើលនៅក្នុងប័ណគ្រួសារអីហោស។

កៈ ចឹងមានន័យថាទាល់មើលនៅក្នុងសៀវភៅគ្រួសារបានមានណាម៉ាក់យាយ?

ខៈ ខ្ញុំអត់ចងចាំទេ។

កៈ បាទចឹងម៉ាក់យាយកើតនៅឆ្នាំ1953ម៉ាក់យាយ?

ខៈ ចឹងហោស។

កៈ បាទម៉ាក់យាយមួយនេះម៉ាក់យាយកើតនៅឆ្នាំ1953?

ខៈ នឹងហើយ។

កៈ ចុះម៉ាក់យាយកើតនៅណាដែរម៉ាក់យាយ?

ខៈ ស្រុកកំណើតនៅតាកែវហោស នៅស្រុកទន្លកហោស។

កៈ ប៉ុន្តែនៅភូមិឃុំអីទៅម៉ាក់យាយ?

ខៈ បាត់ជុងជុន ខេត្តតាកែវ ស្រុកគិរីវង្ស។

កៈ បាត់ជុងជុននឹងភូមិរឺ មួយក៏ឃុំដែរម៉ាក់យាយ?

ខៈ បាត់ជុងជុននឹងវាឃុំបាត់ជុងជុន។

កៈ ចុះភូមវិញ?

ខៈ ភូមិ នៅស្រុកទំលាប់។

កៈ ស្រុកទំលាប់ខេត្តតាកែវ?

ខៈ ខេត្តតាកែវ ភូមិជ្រោយស្លែង។

កៈ អូ៎!!ភូមិជ្រោយស្លែង ចុះម៉ាក់យាយមានបងប្អូនចំនួនប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខ៖  ខ្ញុំមានបងប្អូនចំនួន3នាក់ដែរប៉ុន្តែអ្នកខ្លះគេទៅថៃ អ្នកខ្លះនឹងនៅឡាវហោស។

ក៖  អូ៎ៗ!!មាននៅឡាវ ហើយនឹងមាននៅថៃទៀតហោស?

ខ៖  ចា៎!!នឹងហើយ។

ក៖  នេះបងប្អូនរបស់ម៉ាក់យាយរឺមួយក៏កូនចៅដែរម៉ាក់យាយ?

ខ៖  នេះបងប្អូនរបស់ខ្ញុំទេ។

ក៖  អូ៎!!បាទម៉ាក់យាយចុះ?

ខ៖  អាមួយនៅឡាវ នឹងហើយមួយទៀតនៅថៃបាត់ឈឹងអស់ហើយនឹង។

ក៖  ចឹងមាន3នាក់ហោសម៉ាក់យាយ?

ខ៖  ចា៎!!មាន3នាក់ទាំងខ្ញុំនឹង។

ក៖  ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខ៖  មានប្រុស2នាក់នឹងស្រីខ្ញុំតែមួយនឹងទេ។

ក៖  អូ៎!!ចុះម៉ាក់យាយជាកូនទីប៉ុន្មានដែរម៉ាក់យាយ?

ខ៖  ខ្ញុំជាកូនបងគេនឹង។

ក៖  អូ៎!!ចុះប្អូនរបស់ម៉ាក់យាយនឹងគាត់មានឈ្មោះអីគេខ្លះដែរទៅម៉ាក់យាយ?

ខ៖  មានឈ្មោះស្អីទេនាមត្រកូលនឹងទេ។

ក៖ ចុះឈ្មោះគាត់ធម្មតានឹងឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖  គេឈ្មោះវុធ។

ក៖  ចុះប្អូនទី3វិញម៉ាក់យាយ?

ខ៖  អាពៅនឹងមានឈ្មោះឈាង។

ក៖  ឈ្មោះឈាងហោសម៉ាក់យាយ
ចុះម៉ាក់យាយគិតថាម៉ាក់យាយធ្លាប់មានអនុស្សាវរីយ៍អី

ជាមួយបងប្អូនរបស់ម៉ាក់យាយដែរទេ ធ្លាប់មានអនុស្សាវរីយ៍ដូចថាធ្លាប់លេងបិទពួនរឺមួយក៏លេងគប់កំប៉ុងអីចឹងហាសម៉ាក់យាយ?

ខ៖ ចេះតែមានហើយនឹងពីក្មេងនឹង។

ក៖ ប៉ុន្តែគេលេងអីគេខ្លះដែរទៅម៉ាក់យាយ?

ខ៖ អ៎ូ!ដល់ពេលដែរច្រើនពេកនឹងមិនដឹងថានិយាយពីស្អីមកខ្លះដែរទេ។

ក៖ ដូចជាលេងឡឹកបាយឡ?

ខ៖ លេងឡឹកបាយឡ លេងលាក់ពួនអីចឹងនឹងលាក់កន្សែងអីចឹងទៅ។

ក៖ ចុះមានទៅស្រែអីទេម៉ាក់យាយ មានទៅចាប់ត្រីចាប់ក្តាមនឹងមានទេ?

ខ៖ ចាប់ត្រី ចាប់ក្តាមនឹងមានទៅដែរ។

ក៖ អ៎ូ!ធ្វើស្រែធ្វើអីជាមួយគ្នាដែរណាម៉ាក់យាយ?

ខ៖ ចាំ!!ធ្វើស្រែនឹង។

ក៖ ប៉ុន្តែម៉ាក់យាយចូលចិត្តលេងអីតែម្តងនឹង
មិញនឹងម៉ាក់យាយលេងតែនេះម៉ាក់យាយចូលចិត្ត
លេងអីជាមួយបងប្អូនរបស់ម៉ាក់យាយចូលចិត្តដែរ?

ខ៖
មិនសូវបានលេងជាមួយប្អូនទេពីព្រោះអីនឹងវានៅតូចៗៗដែរនឹងចឹងមិនដឹងលេងស្អីទេ។

ក៖ ប៉ុន្តែលេងបាយខំ នឹងលេងកូនប៉ែងអីម៉ាក់យាយចូលចិត្តលេងទេ?

ខ៖ មានតែចាក់នុំក្រួកដីអីនឹង។

ក៖ អ៎ូ!!លេងចាក់នុំក្រួកដីអីនឹងហោសម៉ាក់យាយ?

ខ៖ មានលេងពូនដីអីនឹងធ្វើជាអង្វែងនឹងទុកចាក់នុំក្រួក។

ក៖ បាទម៉ាក់យាយ?

ខ៖ ចាក់ទឹកទៅនុំនៅចាប់នឹងដីនឹងហាស។

កៈ បាទម៉ាក់យាយបាទ?

ខៈ នៅស្រុកចំការនឹងហាស។

កៈ ចុះប្អូនរបស់ម៉ាក់យាយគាត់នៅណាដែរម៉ាក់យាយ?

ខៈ អាមួយនឹងនៅឡាវហោសមានប្រពន្ធនៅឡាវហោស។

កៈ អូ៎!!ចឹងហោស?

ខៈ អាមួយនៅថៃហោសគេនាំប្រពន្ធគេពីទំលាប់នឹងទៅពីស្រុកនឹងទៅ

កៈ ប៉ុន្តែពួកគាត់ធ្វើអីគេដែរនៅណុងហាសម៉ាក់យាយ?

ខៈ ទៅស៊ីឈ្នួលគេដែរនឹងធ្វើខាងរោងចក្រត្រីខ។

កៈ នឹងនៅថៃហីម៉ាក់យាយ?

ខៈ អានៅឡាវនោះគ្នាដើររ៉ែស្ពឺគេនោះ។

កៈ ជីករ៉ែ ជីកត្បូងហីម៉ាក់យាយ?

ខៈ មិនមែនជីកត្បូងទេជីករ៉ែស្ពឺគេទេតែឥឡូវនឹងឈប់ធ្វើហើយនឹង។

កៈ អូ៎!!បាទម៉ាក់យាយ?

ខៈ

ដូចថាឈប់ខាងណុងហើយដូចថានៅផ្ទះមើលធ្វើជួសជុលខាងគ្រឿងកង់អីចឹងទៅស៊ីប្រចាំថ្ងៃនឹង ហាសចឹង។

កៈ បាទម៉ាក់យាយបាទ?

ខៈ នឹងរឿងប្រចាំថ្ងៃនឹង។

កៈ ចុះឪពុករបស់ម៉ាក់យាយនឹងមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ ឪពុករបស់ខ្ញុំនឹងឈ្មោះរឿន នឹម។

កៈ ចុះគាត់អាយុប៉ុន្មានដែរឥឡូវនឹង?

ខ៖  ពេលដែរគាត់ស្លាប់នឹងអាយុប៉ុន្មានទេសៃជាងហាហើយនឹងមើលទៅ។

ក៖  អូ៎!!ប៉ុន្តែគាត់ស្លាប់បាត់យូរហើយណម៉ាក់យាយ?

ខ៖  យូរដែរហើយនឹងគាត់ស្លាប់យូរដែរហើយនឹង។

ក៖  ចុះឪពុករបស់ម៉ាក់យាយនឹងកាត់កើតនៅណាដែរម៉ាក់យាយ?

ខ៖  ពីណាគេ?

ក៖  ឪពុកម៉ាក់យាយគាត់កើតនៅណាដែរម៉ាក់យាយ?

ខ៖  កើតនៅស្រុកណុងដែរនឹង នៅណុងដែរ។

ក៖  អូ៎!!បាទចុះម្តាយរបស់ម៉ាក់យាយនឹងគាត់មានឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖  ម្តាយរបស់ខ្ញុំនឹងឈ្មោះនាង ស្រទុន។

ក៖  គាត់ឈ្មោះនាង ស្រទុន ចុះគាត់ប្អូនតាប៉ុន្មានឆ្នាំដែរទៅ?

ខ៖  គាត់មានតែបងវិញនឹង។

ក៖  គាត់បងអាយុតាវិញហោសម៉ាក់យាយ?

ខ៖  គាត់ឆ្នាំខាលនឹង ឪបុករបស់ខ្ញុំនឹងឆ្នាំថោះ។

ក៖  អូ៎!!បាទម៉ាក់យាយ?

ខ៖  គាត់ខុសគ្នាមួយឆ្នាំនឹង។

ក៖  ចុះសំរាប់យាយគាត់កើតនៅណាដែរទៅម៉ាក់យាយ?

ខ៖  គាត់កើតនៅណុងដែរនឹងនៅទំលាប់នឹង។

ក៖

អូ៎!!បាទចុះសំរាប់តាគាត់ពីគាត់នៅរស់នឹងកាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ?

ខ៖  ឪពុកខ្ញុំនឹងហោស?

ក៖  បាទម៉ាក់យាយ?

ខ៖ គាត់ចិញ្ចឹមគោ គាត់ចិញ្ចឹមគោធ្វើស្រែអីនឹងហាស។

ក៖ អូ្ហ!!ប៉ុន្តែកាត់មានធ្លាប់បើកអាជីវកម្មលក់ដូរអីទេ?

ខ៖ អត់ទេបើម៉ែរបស់ខ្ញុំនឹងបានលក់។

ក៖ គាត់លក់អីគេដែរទៅម៉ាក់យាយ?

ខ៖ ម៉ែរបស់ខ្ញុំនឹងគាត់ទិញផ្លែឈើនៅនេះចឹងទៅលក់នៅវៀតណាមនឹង។

ក៖ ប៉ុន្តែគាត់ធ្លាប់ធ្វើស្រែអីដែរតើហីម៉ាក់យាយ?

ខ៖ ចា៎!!ថាម៉េច?

ក៖ ម្តាយរបស់ម៉ាក់យាយហាស?

ខ៖ ម្តាយរបស់ខ្ញុំនឹងគាត់ធ្វើស្រែដែរនឹងហាស។

ក៖ អូ្ហ!!បាទចុំឪពុករបស់ម៉ាក់យាយនឹងគាត់កាច រឺមួយក៏ស្លូតដែរម៉ាក់យាយ?

ខ៖ គាត់មិននេះប៉ុន្មានទេពីព្រោះអីនឹងកុំអោយតែខុសនឹង តែខុសគាត់កាចហើយនឹង តែនេះទេគាត់ស្លូតនឹងគ្មានអី។

ក៖ អូ្ហ!!បាទម៉ាក់យាយ ចុះម្តាយរបស់ម៉ាក់យាយ?

ខ៖ ម៉ែរបស់ខ្ញុំនឹងគាត់កាចតែជាមួយកូនចៅទេ
គាត់គ្មានកាចអីនៅខាងក្រៅជាមួយគេទេ។

ក៖ បាទៗៗម៉ាក់យាយ?

ខ៖ គាត់ណែនាំកូនចៅអោយល្អនឹង។

ក៖
ចុះសំរាប់ម៉ាក់យាយមានចងចាំថាកាលពីម៉ាក់យាយនៅជាមួយឪពុកម្តាយរបស់ម៉ាក់យាយនឹង ធ្លាប់មានអនុស្សាវរីយ៍អីជាមួយគ្នាដែរទេទៅស្រែ ញ៉ាំបាយជុំគ្នារឺមួយក៏ធ្វើអីចឹងហាស?

ខ៖ ញ៉ាំបាយជុំគ្នានឹងធ្វើស្រែជាមួយគ្នានឹង គាត់ទៅលក់ដូរមកចិញ្ចឹមយើងតែប៉ុណ្ណឹង។

ក៖ ចឹងហោសម៉ាក់យាយ?

ខ៖ យើងនៅផ្ទះបោកខោអាវអោយគាត់ចឹងទៅណាស់។

ក៖ បាទត្រូវហើយម៉ាក់យាយ?

ខ៖ នៅដាំបាយដាំទឹកអីនឹង។

ក៖ ចឹងហោសម៉ាក់យាយ ប៉ុន្តែធ្លាប់មានអនុស្សាវរីយ៍មានអីថាធ្លាប់ដើរលេងអីជាមួយគ្នា ម្ដាយឪពុករបស់ម៉ាក់យាយធ្លាប់នាំម៉ាក់យាយទៅដើរលេងអីនៅណាដែរទេ?

ខ៖ ម៉ែឪរបស់ខ្ញុំនឹងមិនដែរនាំខ្ញុំទៅដើរលេងទេកាលពីជំនាន់ណុងផ្សេង

ក៖ អូ៎!!ចឹងហោសម៉ាក់យាយ?

ខ៖ ចា៎!ដូចថាជំនាន់ណុងមិនមែនដូចជំនាន់ឥឡូវនឹងទេចេះតែដើរហើរទេអត់មានទេ ដឹងតែពីរកលក់ដូរហូបចុកនឹង។

ក៖ បាទម៉ាក់យាយបាទ?

ខ៖ ម្ហូបឆ្ងាញ់ៗៗតែម្ដងនឹងបានលុយមកហូបឆ្ងាញ់ៗៗណាស់។

ក៖ បាទម៉ាក់យាយបាទ?

ខ៖ បើថានាំទៅដើរលេងនឹងមានតែនាំទៅវត្តទៅវ៉ាអីទេនឹង គ្មានដើរលេងទៅមើលកុន មើលល្ខោនអីនឹងអត់មានទេ។

ក៖ ចឹងអត់មានទេណាម៉ាក់យាយ?

ខ៖ បើទៅមើលល្ខោនអីនឹងមានដែរមានខ្លះៗៗនឹង
កុនអីនឹងគ្មានទេទាល់តែនៅភ្នំពេញនឹងបានមាន។

ក៖ អូ៎ៗ!ប៉ុន្តែយើងនៅស្រុកស្រែណាម៉ាក់យាយ?

ខ៖
នឹងហើយនៅស្រុកស្រែគេគ្មានទេនឹងហើយយើងចង់មើលកុននឹងទាល់តែមកភ្នំពេញនឹង បានមាន។

កះ  បាទម៉ាក់យាយ

ចុះសំរាប់ឪពុករបស់ម៉ាក់យាយនឹងកាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទៅម៉ាក់យាយដែរទេម៉ាក់យាយ?

ខះ  អត់ទេគាត់មិនដែរប្រាប់ទេនឹង។

កះ  អូ៎!!ចឹងកាលពីគាត់នៅកំលោះនឹងក៏គាត់មិនដែរនិយាយដែរហោសម៉ាក់យាយ?

ខះ  អត់ទេ។

កះ

ចុះម្តាយរបស់ម៉ាក់យាយអីនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិអីកាលពីគាត់នៅក្មេងទៅម៉ាក់យាយទេ?

ខះ  ខ្ញុំដូចជាមិនបានលឺនិយាយប្រាប់អីទេនឹង គ្រាន់តែខ្ញុំដឹងថាពេលដែរខ្ញុំធំឡើងនឹងគាត់រកស៊ីលក់ដូរអី នឹងហាស។

កះ  បាទម៉ាក់យាយត្រូវនឹង?

ខះ  គាត់ប្រាប់ចឹង។

កះ

បាទត្រូវហើយម៉ាក់យាយចុះយាយតាខាងឪពុកនឹងម៉ាក់យាយមានស្គាល់ឈ្មោះគាត់ដែរទេ?

ខះ  អូ៎!!យើងនៅតូចចឹងអត់ដឹងទេ។

កះ  ចឹងអត់ស្គាល់ឈ្មោះគាត់ទេណាម៉ាក់យាយ?

ខះ  ខ្ញុំអត់ដឹងទេនឹងពេលនេះនឹងគាត់ស្លាប់បាត់អស់ហើយនឹង។

កះ  ប៉ុន្តែមានដឹងថាគាត់កើតនៅណាដែរទេម៉ាក់យាយ?

ខះ  គាត់កើតនៅស្រុកដែរនឹងប៉ុន្តែដូចថាគាត់នៅភូមិអីខាងលិចទំលាប់នេះស្អីគេទេនេះ។

កះ  អូ៎!!ខ្ញុំអត់ស្គាល់ដែរនឹងម៉ាក់យាយ?

ខះ  ខ្ញុំភ្លេចដែរហើយនឹងដូចជានៅព្រៃចេក រឺក៏ដើមបេងអីចឹង។

កៈ បាទម៉ាក់យាយ ចុះយាយតាខាងម្ដាយម៉ាក់យាយមានស្គាល់ដែរទេម៉ាក់យាយ?

ខៈ អត់ស្គាល់ដែរនឹង។

កៈ ចឹងអត់ស្គាល់ដូចគ្នាណាម៉ាក់យាយ?

ខៈ នឹងហើយអត់ស្គាល់ដែរ។

កៈ ប៉ុន្តែពួកគាត់កើតនៅស្រុកជាមួយគ្នាមែនមីង?

ខៈ
នឹងហើយគាត់នៅស្រុកជាមួយម៉ែរបស់ខ្ញុំនឹងប៉ុន្តែយើងមិនដឹងស្អីទេគាត់កើតមកនឹងនៅតូចនឹង។

កៈ បាទម៉ាក់យាយ?

ខៈ កាលណុងនឹង។

កៈ ចុះម៉ាក់យាយមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅម៉ាក់យាយ?

ខៈ ខ្ញុំមកនៅនឹងតាំងពីឆ្នាំ1981ហោស។

កៈ ចឹងនៅឆ្នាំ1981ហោសម៉ាក់យាយ ចឹងម៉ាក់យាយមកនៅអស់37ឆ្នាំ?

ខៈ មិនដឹងថាប៉ុន្មានទេនឹង។

កៈ
ចឹងសំរាប់ម៉ាក់យាយមានបងប្អូនរឺមួយក៏កូនចៅណាដែរទៅរស់ក្រៅប្រទេសទេម៉ាក់យាយក្រៅពីស្រុកខ្មែរហោសម៉ាក់យាយ?

ខៈ អត់មានទេមានតែមួយនៅឡាវនឹងមួយនឹងថៃនឹង។

កៈ អូ!!ចឹងមានពីរនាក់នៅឡាវនឹងនៅថៃណាម៉ាក់យាយ?

ខៈ មានតែនៅឡាវ នឹងនៅថៃនឹង។

កៈ អូ!!បាទចឹងស្វាមីរបស់ម៉ាក់យាយមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ គាត់មានឈ្មោះខុង សុខំ។

កៈ ឈ្មោះខុង សុខំ ហោសម៉ាក់យាយ?

ខៈ នោះតាហោស។

កៈ តានៅក្រោយហោសម៉ាក់យាយ?

ខៈ នោះរូបថតហោស។

កៈ រូបថតហោសម៉ាក់យាយ?

ខៈ គាត់ធ្វើការដែរតើពីដើមនឹង។

កៈ អូ៎!!បាទម៉ាក់យាយបាទ?

ខៈ គាត់ខំតស៊ូណាស់។។

កៈ ចុះម៉ាក់យាយមានដឹងថាម៉ាក់យាយការនៅថ្ងៃខែឆ្នាំណាដែរម៉ាក់យាយ?

ខៈ ខ្ញុំអត់ចាំទេខ្ញុំការតាំងពីឆ្នាំ1970ណោះនឹង។

កៈ តាំងពីឆ្នាំ1970ហោសម៉ាក់យាយ?

ខៈ ចាំ!!នឹងហើយនៅឆ្នាំ1970នឹង។

កៈ ចុះកូនរបស់ម៉ាក់យាយនឹងឥឡូវនឹងអាយុប៉ុន្មានដែរម៉ាក់យាយ?

ខៈ កូនរបស់ខ្ញុំនឹង។

កៈ បងធំគេបង្អស់ហាសម៉ាក់យាយ?

ខៈ កូននឹងអាបងនឹងប្រហែលជាអាយុសែជាងហើយឥឡូវនឹង។

កៈ អូ៎!!សែជាងហើយហោស?

ខៈ នឹងហើយអាបន្ទាប់នឹងអាយុសាមជាងហើយនឹង។

កៈ ដោយសារតែបងធំនឹងប្រហែលជិតហាសសិបហើយនឹង?

ខៈ នឹងហើយឆ្នាំឆ្លូវហាសអាស្លាប់ទៅនឹងហាសនៅជំនាន់អាពតនឹងហាស។

កៈ នៅឆ្នាំ1970នឹង?

ខ៖  ស្លាប់នៅជំនាន់អាពតនឹង។

ក៖  ចឹងសំរាប់?

ខ៖ នឹងហើយស្លាប់4-5ឆ្នាំនឹងហើយតូចជាងនឹង។

ក៖  មានតូចជាងនឹងទៀត ?

ខ៖  កូនប្រុសនឹងវាវាគទាល់តែស្លាប់។

ក៖
ចឹងនៅពេលដែរម៉ាក់យាយការហើយនឹងម៉ាក់យាយទំនេរពោះសិនរឺយ៉ាងម៉េចដែរម៉ាក់យាយ?

ខ៖  នៅទំនេរពោះសិនទំនេរពោះ4-5ខែនឹងហាស។

ក៖  ចឹងទំនេរពោះ4-5ខែហើយណាម៉ាក់យាយ?

ខ៖  ចឹងហើយបាន។

ក៖  ចឹងម៉ាក់យាយការអស់48ឆ្នាំ ចឹងសំរាប់នៅពេលដែរម៉ាក់យាយរៀបការជាមួយតានឹង គិតថាម៉ាក់យាយរៀបការដោយខ្លួនឯងរឺក៏ឪពុកម្តាយជាអ្នករៀបចំដែរ?

ខ៖  ទេឪពុកម្តាយជាអ្នករៀបអោយអូជំនាន់ណុងតឹងណាស់។

ក៖  កាលពីជំនាន់ណុងយើងមិនចេះតែរៀបចំដោយខ្លួនឯងទេហោសម៉ាក់យាយ?

ខ៖  មិនមែនទេនឹងខ្ញុំអត់ចេះស្រលាញ់ផងនឹងអត់ចេះស្រលាញ់ផងនឹងពេលណុង។

ក៖  ប៉ុន្តែមានជាជំនួនអត់ម៉ាក់យាយ
ពេលដែរតាចូលស្តីដណ្តឹងម៉ាក់យាយនឹងមានជាជំនូនទេ?

ខ៖  ខាងប្រុសនឹងហោស?

ក៖  បាទម៉ាក់យាយបណ្ណាការហាសថ្លៃទឹកដោះហាស?

ខ៖  មានដែរតើ!!នឹង។។

ក៖  កាលណុងគេអោយអីគេដែរម៉ាក់យាយ?

ខ៖ ម៉ែរបស់ខ្ញុំនឹងយកថ្លៃផ្ទះនឹងតាំងពីណុងគាត់អោយធ្វើផ្ទះទេណាស់។

ក៖ បាទម៉ាក់យាយបាទ?

ខ៖ ពេលគេអោយមួយដំឡឹងនឹង។

ក៖ អ៎ូ!មួយដំឡឹងហោស?

ខ៖ នឹងហើយយកមាសនឹងយកមួយដំឡឹងនឹងគេហ៊ានរត់បានយើងបានជួបគ្នាទៅ។

ក៖ អ៎ូ!!ថ្លៃណាស់ម៉ាក់យាយ?

ខ៖ កាលជំនាន់ថ្លៃណាស់។

ក៖ ចុះពេលណុងម៉ាក់យាយធ្លាប់ស្គាល់តាពីមុនអត់ចឹង?

ខ៖ ដូចថាស្រុកភូមិចឹងទៅនៅជិតគ្នាចឹងទៅ។

ក៖ ប៉ុន្តែធ្លាប់ឃើញគ្នាពីមុនដែរអត់?

ខ៖ គ្រាន់តែថាមិនដែរ។

ក៖ អត់ដែរទាក់ទងគ្នាទេ?

ខ៖ អត់ដែរបានទាក់ទងទេអត់ទេ។

ក៖ អត់ដែរបានទាក់ទងគ្នាទេម៉ាក់យាយណា
ចុះម៉ាក់យាយមានចេះភាសាអីក្រៅពីភាសាខ្មែរទេ?

ខ៖ អត់ចេះទេ។

ក៖ ភាសាវៀតណាម ភាសាអី?

ខ៖ ភាសាវៀតណាមនឹងខ្ញុំចេះខ្លះដែរពីព្រោះអីនឹង
ស្រុកណុងគេទៅរកស៊ីនៅវៀតណាម។

ក៖ ចុះភាសាថៃម៉ាក់យាយចេះទេ?

ខ៖ ភាសាថៃខ្ញុំអត់ចេះទេ។

កៈ ចុះម៉ាក់យាយមានចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរម៉ាក់យាយ?

ខៈ ភាសាខ្មែរអត់មានបានរៀនសោះ។

កៈ ចឹងអត់ដែរចូលរៀនសោះតែម្តងនឹងហោសម៉ាក់យាយ?

ខៈ អត់ផងនឹង។

កៈ
ចុះកាលពីនៅក្មេងៗហាសតើម៉ាក់យាយធ្លាប់មិត្តភក្តិជាមួយគ្នាទេមិត្តភក្តិជិតស្និទ្ធិហាស?

ខៈ
មិត្តភក្តិជិតស្និទ្ធិខ្ញុំប្រាប់ខ្ញុំចង់និយាយថាអត់មានដូចគេមានមិត្តភក្តិអត់មានទេឪពុករបស់ខ្ញុំនឹងកាច ដែរនឹងហាស។

កៈ ប៉ុន្តែគ្រាន់តែមិត្តភក្តិយើងដើរលេងជាមួយគ្នាអីនឹងក៏អត់មានដែរ?

ខៈ អត់មានទេ ខ្ញុំនៅតែផ្ទះនឹងនៅមើលតែមាន់ដាំតែបាយនឹងមើលជ្រូកនឹងហាស។

កៈ អូ៎!!បាទម៉ាក់យាយ?

ខៈ អត់ដែរទៅណាទេខ្ញុំនឹងហោសបើរៀងដើរហើរអត់មានសោះ។

កៈ
ចុះសំរាប់ការពីក្មេងនឹងរហូតមកដល់ពេកនេះម៉ាក់យាយធ្លាប់បានធ្វើការងារអីគេខ្លះដែរទៅ?

ខៈ ពីក្មេងនឹងខ្ញុំនៅជាមួយម៉ែអត់ធ្វើទេខ្ញុំដាំតែបាយអោយគាត់ហូបទៅណាស់។

កៈ បាទម៉ាក់យាយ?

ខៈ ពីព្រោះគាត់ដើររកស៊ីចិញ្ចឹមយើងហោស ដល់ពេលដែរមានប្តីនឹងមកចេះលក់បបរ លក់នុំបញ្ចុះអីចឹងទៅ។

កៈ បាទម៉ាក់យាយ?

ខៈ ដល់ពេលដែរក្រោយនឹងមកឈប់ធ្វើមុខរបរចឹងទៅធ្វើការងារនៅរោងចក្រម្តងនឹង រោងចក្រនឹងយើងនៅខាងអនាម័យនឹងសំអាតរោងចក្រ។

កះ  នៅណាវិញម៉ាក់យាយ?

ខះ  នេះនៅរោងចក្រជិតនឹងខ្ញុំធ្វើ5ឆ្នាំហើយនៅរោងចក្រនឹង។។

កះ  បាទត្រូវហើយម៉ាក់យាយ?

ខះ  យើងអាយុហុកជាងនឹងគេមិនហ៊ានប្រើទេ។

កះ  ចុះម៉ាក់យាយគិតថាម៉ាក់យាយធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរទេ
ធ្វើស្រែចំការហាសម៉ាក់យាយ?

ខះ  មិនធ្វើប៉ុន្មានទេខ្ញុំពីតូចនឹងខ្ញុំស្រណុកដែរនឹង។

កះ  អ្ហូ!ចឹងហោសម៉ាក់យាយ?

ខះ  នៅមើលតែផ្ទះនឹងដាំបាយ
បោកខោអាវអោយម៉ែឪតិចតួចនឹងហើយគាត់ដើររកស៊ីចិញ្ចឹមកូននឹង។

កះ  បាទម៉ាក់យាយចុះម៉ាក់យាយធ្លាប់ចិញ្ចឹមសត្វរឺមួយក៏លក់ដូរអីទេម៉ាក់យាយ?

ខះ  នឹងៗៗចិញ្ចឹមជ្រូកចិញ្ចឹមអីនឹងអោយជ្រូកស៊ីនឹងបុកដើមចេកហាន់ដើមចេកនឹង។

កះ  ចិញ្ចឹមច្រើនដែរទេម៉ាក់យាយ?

ខះ  ចិញ្ចឹមមួយពីរនឹង។

កះ  អ្ហូៗ!!ប៉ុន្តែម៉ាក់យាយធ្លាប់ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមគោ ក្របីអីទេម៉ាក់យាយ?

ខះ  ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមគោនឹងឪរបស់ខ្ញុំនឹងមានទាំងអស់នឹង។

កះ  ប៉ុន្តែម៉ាក់យាយចិញ្ចឹម?

ខះ  ខ្ញុំមិនដែរទៅច្រូតស្មៅអីអោយគោស៊ីទេមានតែឪពុកទេ។

កះ  ប៉ុន្តែម៉ាក់យាយចិញ្ចឹមលក្ខណះជាច្រើនរឺធម្មតា?

ខះ  ចិញ្ចឹមតែមួយគូរទេនឹងមួយនឹមនឹងគោ មួយនឹមនឹង។

កះ  អ្ហូ!!ចឹងហោសម៉ាក់យាយ?

ខ៖ ទុកគ្រាន់តែធ្វើស្រែនឹង។

ក៖ មាន់ចិញ្ចឹមតិចដែរណាម៉ាក់យាយ?

ខ៖ មាន់មានចិញ្ចឹមរាប់រយក្បាលនឹងដែរនឹង។

ក៖ អ្ហូ!!ចឹងមានចិញ្ចឹមលក្ខណះជាកសិដ្ឋានហើយណាម៉ាក់យាយ?

ខ៖ គ្មានអីនេះទេប៉ុន្តែឪរបស់ខ្ញុំនឹងចេះខ្ញុំប្រាប់អោយអស់មាន់ផ្ទះរបស់ខ្ញុំនឹង
គ្មានអាចយកទៅសែនបានទេ។

ក៖ ម៉េចចឹងម៉ាក់យាយ?

ខ៖ ពីព្រោះគេយកទៅជល់ឪពុករបស់ខ្ញុំនឹងមិនអោយយកទៅសែនទេ។

ក៖ អ្ហូ!!បាទម៉ាក់យាយ?

ខ៖ ប៉ុន្តែបើយកទៅហូបបាន បើយកទៅហូបបាន។

ក៖ បើជល់ចាញ់យកទៅហូបទៅណាម៉ាក់យាយ?

ខ៖ នឹងហើយយកទៅសែននឹងអត់ទេដូចថាវាសាបគាត់ហាស។

ក៖ បាទៗត្រូវហើយម៉ាក់យាយ?

ខ៖ គាត់ធ្លាប់តែជល់មាន់។

ក៖ បាទត្រូវចុះម៉ាក់យាយគិតថាម៉ាក់យាយធ្លាប់បើកមុខរបរអាជីវកម្មអីផ្សេងដែរទេ?

ខ៖
ដល់ពេលដែរខ្ញុំឡើងមកនៅភ្នំពេញនឹងបានខ្ញុំចេះលក់ឥវ៉ាន់ចាប់ហ៊ួយអីបន្តិចបន្តួចនឹង។

ក៖ អ្ហូ!!បាទម៉ាក់យាយ?

ខ៖ ទាល់មកនឹងទៅអត់មានលក់ទៀតទេ។

ក៖ បាទម៉ាក់យាយ?

ខ៖ ខ្ញុំមកមុននឹងខ្ញុំមកនៅច្បារអំពៅនឹងហោស។

កៈ បាទម៉ាក់យាយ?

ខៈ ដល់ពេលដែរខ្ញុំចេញពីច្បារអំពៅទៅបានខ្ញុំមកនៅនឹង។

កៈ បាទចឹង?

ខៈ នៅនឹងមានលក់បបរ លក់អីនឹងមុខរោងចក្រអីចឹងមានបាយស្រូបអីទេ
ដល់ក្រោយនឹងបានខ្ញុំឈប់ មុខរបរចឹងទៅបានខ្ញុំធ្វើការនៅរោងចក្រចឹងទៅ។

កៈ បាទម៉ាក់យាយចឹងសំរាប់ម៉ាក់យាយគិតថាជីវិតរបស់ម៉ាក់យាយនឹង?

ខៈ វាយ៉ាប់ដែរនឹងវានឿយដែរនឹងអូន។

កៈ
ចុះម៉ាក់យាយគិតថាជីវិតរបស់ម៉ាក់យាយមានការផ្លាស់ប្ដូរអីគេខ្លះដែរតាំងពីក្មេងរហូតមក
ដល់ ពេលនេះហាសម៉ាក់យាយ?

ខៈ ពីក្មេងនឹងយើងនៅជាមួយម៉ែឪនឹងគ្មានធ្វើអីទេ
ដល់ពេលដែរការហើយចេះតែចង់បានចង់មានចឹង
ទៅក៏យើងលក់នេះលក់នោះអីចឹងទៅលក់នុំ។

កៈ បាទម៉ាក់យាយចុះគិតថាជីវភាពនឹងយ៉ាងម៉េចដែរម៉ាក់យាយ?

ខៈ អើយកូនអើយជីវភាពឥឡូវនឹងវាយ៉ាប់ដែរនឹង បានកូនគេជួយចិញ្ចឹមដែរនឹង។

កៈ ចឹងហោសម៉ាក់យាយ ចុះគិតថាសុខភាពឥឡូវនឹងយ៉ាងម៉េចដែរម៉ាក់យាយ?

ខៈ សុខភាពខ្ញុំនឹងអត់ស្រួវដែរនឹងវាឈឺចឹងទៅណាស់អូន។

កៈ ឈឺមួយថ្ងៃកាត់មួយថ្ងៃកោរចឹង?

ខៈ ឈឺមួយថ្ងៃកាត់មួយថ្ងៃកោរចឹងហាស។

កៈ ចុះម៉ាក់យាយគិតថាម្ហូបអីគេដែរម៉ាក់យាយចូលចិត្តពិសារដែរម៉ាក់យាយ?

ខៈ ឥឡូវនឹងតែអស់ធ្មេញហើយនឹងមានតែសាច់ទេ។

កៈ អូ!!បាទម៉ាក់យាយ?

ខ៖ មានតែញ៉ាំសាច់ទេនមឹង។

ក៖ សាច់នឹងភាគច្រើននឹងយកទៅធ្វើជាម្ហូបអីគេដែរម៉ាក់យាយ?

ខ៖ សាច់មាន់យកមករលីងប្រៃនឹង។

ក៖ អូ្ន!!យកមកលីងប្រៃនឹងហោសម៉ាក់យាយ?

ខ៖ នឹងហើយរលីងប្រៃចឹងទៅយកមកស្ងោរសាបយកជ្រលក់ទឹកត្រីនឹង។

ក៖ បាទម៉ាក់យាយ?

ខ៖ ខ្ញុំហូបបានតែប៉ុណ្ណឹងទេ ដូចថាម្ហូរគ្រឿងម្ហូរអីនឹងដូចជាធ្លមតែម្ដងនឹង។

ក៖ បាទចុះសំរាប់ម៉ាក់យាយ?

ខ៖ សំរាប់ឆាអីនឹងធ្លមដែរ។

ក៖ ចុះម៉ាក់យាយគិតថាល្បែងប្រជាប្រិយ៍អីដែរម៉ាក់យាយចូលចិត្តលេងតាំងពីក្មេងហាស?

ខ៖
ពីក្មេងនឹងមានតែចឹងដូចខ្ញុំនិយាយចឹងពូនដីចឹងទៅហើយនេះចុះចឹងទៅវាទៅជានុំក្រួកហើយនឹង។

ក៖ ចុះប៉ុន្តែសំរាប់?

ខ៖ ខ្ញុំលេងតែចឹងៗៗនឹង
ហើយម៉ែដល់ពេលឃើញចឹងបានទៅទិញបាយឡឹកបាយឡអោយលេងចឹងទៅណាស់។

ក៖ អូ្ន!!ម៉ាក់យាយលេងឡឹកបាយឡនឹងហោស?

ខ៖ គាត់ទិញចឹងទៅអោយលេងចឹងទៅ។

ក៖ ប៉ុន្តែម៉ាក់យាយគិតថាដូចជាលេងចោលឈូង បោះអង្គុញ ទាញព្រាត លាក់កន្សែង?

ខ៖ អត់សូវទេនឹង។

ក៖ ចឹងអត់សូវទេណាម៉ាក់យាយ?

ខ៖ អត់មានសូវទេពីព្រោះឪរបស់ខ្ញុំនឹងអត់នឹងមានស្រីមានប្រុសចឹងហាសអត់អោយទេ។

កៈ បាទម៉ាក់យាយ?

ខៈ ចូលឆ្នាំមានក្រមុំកមលោះនឹងគាត់អត់អោយទេ។

កៈ ចុះសំរាប់ម៉ាក់យាយនឹងចេះច្រៀងទេ?

ខៈ អត់ទេចុះបើអត់ចេះអក្សរផងនឹង។

កៈ ចុះម៉ាក់យាយចូលចិត្តស្តាប់បទចំរៀងទេម៉ាក់យាយ?

ខៈ ចូលចិត្តស្តាប់ដែរតើខ្ញុំឥឡូវនឹង។

កៈ លក្ខណៈបទបុរាណរឺមួយក៏បទសម័យដែរម៉ាក់យាយ?

ខៈ បទបុរាណនឹង។

កៈ អូ៎!!បុរាណហោសម៉ាក់យាយ?

ខៈ រញ៉ាក់រញ៉ូរនឹងខ្ញុំមិនចូលចិត្តទេ។

កៈ បាទចុះ?

ខៈ រាំងវង្ស លាំលាវអីនឹងចូលចិត្តណាស់។

កៈ អូ៎!!បាទម៉ាក់យាយ?

ខៈ អោយតែបទកំសត់នឹងពីដើមនឹង។

កៈ ចុះឃីកេអាយៃអីម៉ាក់យាយចូលចិត្តដែរទេ?

ខៈ នឹងៗៗហើយខ្ញុំក៏ចូលចិត្តដែរនឹង។

កៈ អូ៎!!បាទម៉ាក់យាយ?

ខៈ កុំអោយតែរញ៉ាក់រញ៉ូរអីនឹងខ្ញុំមិនចូលចិត្តទេនឹង។

កៈ ស្តាប់ធិមអីនឹងម៉ាក់យាយចូលចិត្តលេខមួយហើយណាម៉ាក់យាយ?

ខៈ ធិមអានឹងខ្ញុំចូលចិត្តដែរនឹង។

កៈ
ចុះម៉ាក់យាយគិតថាផ្ទះរបស់ម៉ាក់យាយមានលក្ខណៈបែបណាដែរតាំងពីក្មេងរហូតមកដល់
ពេលនេះហាសម៉ាក់យាយកាលពីក្មេងនឹងផ្ទះយ៉ាងម៉េចហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹង?

ខៈ
ផ្ទះដូចតែរាល់ថ្ងៃនឹងផ្ទះប៉ុណ្ណឹងក្រចឹងមានស្អីទៀតនឹងគ្រាន់ថាបើអោយមានលុយដំឡើងតិចនឹង
គ្មានទេមានតែថ្ងៃស្រុខទៅហើយនឹងចុះយើងមួយថ្ងៃនឹងមិនដែររកបានមួយរយលុយខ្មែរចូលផងនឹង អូនឯងគិតមើល។

កៈ អូ៎!!បាទម៉ាក់យាយត្រូវហើយ?

ខៈ បើយើងទៅស៊ីឈ្នួលគេយើងបានអានឹងយើងបាន
តែបើថាអត់បានស៊ីឈ្នួលគេផងនឹង។

កៈ
បាទម៉ាក់យាយចុះម៉ាក់យាយគិតថាផ្ទះរបស់ម៉ាក់យាយនឹងនរណាគេជាអ្នកសាងសងដែរ?

ខៈ នៅពេលដែរខ្ញុំមកនឹងទិញស្រាប់តែម្តងនឹង។

កៈ អូ៎!!ចឹងមានន័យថាអត់ដឹងថានរណាគេជាអ្នកធ្វើទេ?

ខៈ អត់ដឹងទេ។

កៈ អូ៎!!បាទម៉ាក់យាយ?

ខៈ នេះផ្ទះគាត់ជិតនឹងគាត់ចែកអោយនឹង។

កៈ
បាទម៉ាក់យាយចុះសំរាប់ម៉ាក់យាយគិតថាធ្វើផ្ទះនឹងគេប្រើឧបករណ៍អីសំរាប់សាងសងដែរទេ?

ខៈ ហាសថាម៉េច?

កៈ សាងសងផ្ទះហាសគេប្រើឧបករណ៍អីសំរាប់សាងសងដែរម៉ាក់យាយ?

ខ៖ អើរខ្ញុំអត់សូវដឹងទេ។

ក៖ ចឹងម៉ាក់យាយអត់សូវដឹងទេណាម៉ាក់យាយ?

ខ៖ ចា៎!!ខ្ញុំអត់សូវដឹងទេខ្ញុំចាស់ហើយនឹង។

ក៖
ចុះឪពុកម្ដាយរបស់ម៉ាក់យាយនឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅម៉ាក់យាយដែរទេ?

ខ៖ អត់ទេនឹង។

ក៖ ដូចលក្ខណៈថាវេញវល្លិ៍ ក្ដូរស្ករ ធ្វើផ្ដៅ ធ្វើជាកន្ទេលអញ្ចូតអីចឹងហាស?

ខ៖ អត់មានទេនៅនឹងអត់មានទេអត់មានមុខរបរជំនាញខាងនឹងផងនឹង។

ក៖ អ្ហ៎!!ចឹងហោសម៉ាក់យាយ?

ខ៖ មានតែមុខរបររកស៊ីនឹងលក់ដូរ។

ក៖ បាទម៉ាក់យាយបាទ?

ខ៖ ម៉ែរបស់ខ្ញុំនឹងទិញលក់ដូរចឹងទៅ។

ក៖ ចឹងសំរាប់ម៉ាក់យាយអាចប្រាប់ពីពេលលំបាករបស់ម៉ាក់យាយបានទេ
ធ្លាប់មានបញ្ហាអីគេខ្លះតាំងពីក្មេងរុះតមកដល់ពេលនេះហាស?

ខ៖ ពីក្មេងដល់ពេលដែរមានប្ដីមានអីចឹងទៅចង់បានចង់មានចេះទៅពិបាកហើយនឹង
ពិបាកទាល់តែឥឡូវនឹងពិបាកទាល់តែដល់ឈឺនឹងបានបានឈប់នឹងហាស
កុំតែឈឺនឹងបើមិនឈឺទេខ្ញុំ នៅតែដើររកការងារដល់ឥឡូវនឹង។

ក៖ អ្ហ៎!!ចឹងទេហោសម៉ាក់យាយ?

ខ៖ ចា៎!!នឹងហើយ។

ក៖
ចុះសំរាប់ពេលដែរពេលពតនឹងម៉ាក់យាយគិតថាមានការលំបាកអីគេខ្លះដែរម៉ាក់យាយ?

ខ៖ អ្ហ៎!!ទៅពលពតនឹងដូចថាវាពិបាកជីវភាពនឹងវាមិនអោយយើងហូបឆ្អែតឆ្អន់ទេ។

កៈ ប៉ុន្តែម៉ាក់យាយ?

ខៈ ពេលធ្វើការ។

កៈ ពេលណុងម៉ាក់យាយនៅអាយុប៉ុន្មានដែរម៉ាក់យាយពេលណុង?

ខៈ ពេលដែរខ្ញុំទៅអាពតនឹងខ្ញុំអាយុ30ឆ្នាំទៅសាមជាងហើយនឹង។

កៈ បាទម៉ាក់យាយ ចុះ?

ខៈ ខ្ញុំទើបតែកូនមួយនឹង។

កៈ បាទៗៗចុះគេអោយម៉ាក់យាយទៅណាដែរទៅពេលណុង?

ខៈ ការហើយនឹងខ្ញុំការអាយុ19ឆ្នាំ។

កៈ បាទម៉ាក់យាយ?

ខៈ អាយុ19ឆ្នាំបានការហាសខ្ញុំទមនេរពោះ5ខែនឹងបានមានកូន។

កៈ បាទម៉ាក់យាយ?

ខៈ ដល់បានកូនមួយនឹងដល់កូនបាន4-5ឆ្នាំហើយបានទៅអាពតនឹង។

កៈ បាទម៉ាក់យាយបាទ?

ខៈ ជំនាន់អាពតនឹងកូនរបស់ខ្ញុំនឹងអាយុ5ឆ្នាំហើយ។

កៈ ប៉ុន្តែកាលពីជំនាន់ពលពតនឹងគេអោយម៉ាក់យាយភៀសខ្លួនទៅណាដែរទៅ?

ខៈ ជំនាន់អាពតនឹងហោស?

កៈ បាទម៉ាក់យាយ?

ខៈ ខ្ញុំទៅពីនេះទៅនឹងទៅនៅកំពង់សោម។។

កៈ អូ៎!!នៅកំពង់សោមហោសម៉ាក់យាយ?

ខៈ នឹងហើយដល់ពេលដែរអាពតនឹងភៀសពីកំពង់សោមនឹងទៅទៅតាមស្រុកចឹងទៅ។

កៈ ទៅឆ្ងាយៗចឹងទៅហោសម៉ាក់យាយ?

ខ៖ ទៅជិតធ្លាក់ដល់តាកែវហោស។

ក៖ ប៉ុន្តែគេមានកន្លែងចាប់ណាមីងគេមានកន្លែងចាប់តំបន់ដើម្បីអោយយើងទៅណាមីង?

ខ៖ តាមពួកអាតពតនឹងហាស។

ក៖ បាទម៉ាក់យាយ?
ខ៖ អាពតវាមានដែរតើ!!វាមានដែរនឹង។

ក៖ អូ៎!!ចឹងបាទម៉ាក់យាយ?

ខ៖
ចឹងវាចេះតែកៀរៗយើងទៅតាមវាចឹងទៅជិតដល់ស្រុកខ្ញុំវិញហោសជិតដល់តាកែវហោស។

ក៖ បាទត្រូវហើយម៉ាក់យាយ?

ខ៖ ធ្លាក់ទៅដល់ព្រៃអម្ពក។

ក៖ ចុះម៉ាក់យាយគិតថាឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរម៉ាក់យាយ?

ខ៖ ការលំបាកនៅក្នុងជំនាន់អាពតនឹងហោស។

ក៖ បាទម៉ាក់យាយ?

ខ៖ មួយថ្ងៃៗធ្វើតែការងារអោយវានឹង ដល់ពេលដែរមកវិញនឹងបាយហូបមិនឆ្អែតទេ។

ក៖ ម៉េចចឹងម៉ាកយាយវាអោយរបបអាហារយើងអត់ដល់មែនម៉ាក់យាយ?

ខ៖ អត់អោយយើងហូបអត់ឆ្អែតផងនឹងវាវាស់វែកហាស។

ក៖ បាទម៉ាក់យាយ?

ខ៖ ពេលដែរវាដាំបាយចឹងគ្រាន់តែវាស់វែកនឹងម្នាក់3វែកចឹងទៅ
ចែកគ្នា8នាក់ចឹងទៅម្នាក់3វែកៗចឹងទៅណាស់ មានបបរចឹងទៅម្នាក់3វែកៗចឹងទៅ
បបរាវកឃ្លោកនឹង។

ក៖ បាទបបរាវកឃ្លោកនឹង?

ខ៖ បបរវាក្រឡេកនឹង។

ក៖ ចឹងមានតែទឹកហើយនឹងកាកទេ?

ខ៖ នឹងហើយមានតែទឹកនឹងអង្ករបន្តិចៗៗនឹងហាស។

ក៖ បាទម៉ាក់យាយ?

ខ៖ ហើយហូបសម្លត្រកួននឹងគ្មានត្រីគ្មានអីណាទេ។

ក៖ កាលពីជំនាន់គេថារកអីអត់បានទេ?

ខ៖ អត់ទេមានតែសំលត្រកួននឹងសំលអីវាស៊ីនឹងហាស ហើយស៊ីម៉េចកើតនឹង។

ក៖ បាទម៉ាក់យាយបាទ?

ខ៖ យើងចេះតែហូបចឹងទៅ

ក៖ បាទម៉ាក់យាយបាទ?

ខ៖ វាមិនឆ្ងាញ់នឹងចេះហូបអោយតែរស់ទៅនឹង។

ក៖ ចូលម៉ាក់យាយគិតថា?

ខ៖ ជួនកាលអាពតនឹងស្ងោរទឹកកំបោរអោយយើងហូបនឹងហូបជាមួយសម្ល។

ក៖
ចុះកាលពីក្មេងនឹងឪពុកម្ដាយរបស់ម៉ាក់យាយនឹងធ្លាប់បង្រៀនអីទៅម៉ាក់យាយទេដូចថាជំនាញ អីដែរទៅម៉ាក់យាយចឹងហាស?

ខ៖ អត់ទេខ្ញុំ។

ក៖ ចឹងអត់ដែរទេណាម៉ាក់យាយ?

ខ៖ ដូចថារកស៊ីអីចឹងយើងទៅមើលគាត់ចឹងទៅ។

ក៖ អូ!!បាទម៉ាក់យាយ?

ខ៖ ដល់ពេលដែរយើងមានប្ដីចឹងទៅយើងចេះតែចែកតាមនឹងចឹងទៅណាស់។

កៈ
ចុះម៉ាក់យាយគិតថាកាលពីក្មេងហាសម៉ាក់យាយគិតថាពេលដែរធំឡើងនឹងម៉ាក់យាយចង់ធ្វើអីគេ ដែរទេម៉ាក់យាយ?

ខៈ អត់រៀនផងនឹងបានចេះស្អីនឹងចេះតែ។

កៈ ប៉ុន្តែម៉ាក់យាយគិតថាខ្លួនចង់ធ្វើជាគ្រូពេទ្យរឺមួយធ្វើជាអ្នករកស៊ី?

ខៈ ធ្វើអីបើអត់ចេះអក្សរផងនឹងខ្ញុំអត់មានប៉ុងចឹងទេ។

កៈ អូ៎!!បាទម៉ាក់យាយបាទ?

ខៈ ខ្ញុំរកស៊ីនឹងទេនឹងហើយ។

កៈ ចុះម៉ាក់យាយគិតថាពេលណាដែរម៉ាក់យាយគិតថាជាពេលដែរ ដែរជាពេលសប្បាយនៅក្នុងឆាកជីវិតរបស់ម៉ាក់យាយហាស?

ខៈ
មិនដឹងថាពេលណាសប្បាយទេបើរាល់ថ្ងៃនឹងកូនវាអត់ជីវភាពខ្វះខាតនឹងអត់សប្បាយទេ។

កៈ អោយសប្បាយម៉េចកើតបើជីវភាពនឹងខ្សត់ខ្សោយនឹង?

ខៈ ចា៎!!

កៈ បើជំងឺនឹងឈឺរហូតនឹងរាំរៃ?

ខៈ
មានតែកើតទុកណាឡើងស្គមឡើងធ្លាក់អស់ហើយណាឃើញអត់ពីមុនខ្ញុំធាត់ហាណាស់ដល់ពេល ឥឡូវនឹងចឹងហាស។

កៈ អូ៎!!បាទចុះបើសិនជាចង់អោយម៉ាក់យាយផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយនឹង តើម៉ាក់យាយចង់ផ្តែផ្តាំអីទៅពួកគាត់ដែរម៉ាក់យាយលក្ខណះថាចង់អោយផ្តែផ្តាំអីគេខ្លះនៅពេលអនាគត់ចឹងហាស?

ខៈ យើងចាស់ហើយមិនដឹងយ៉ាងម៉េចទេ។

កៈ
ប៉ុន្តែយើងចង់ផ្តែផ្តាំទៅចៅចឹងលក្ខណៈថាពេលអនាគត់ចឹងចង់អោយចៅធ្វើអីចឹងហាស?

ខៈ បើរឿងចៅមានតែអោយខំប្រឹងរៀនសូត្រ បានបានវាចេះបានធ្វើជាគ្រូអីនឹងគេចឹងទៅ កូនប្រុសធ្វើការងារអើរទៅស្រុកគេអីចឹងទៅណាស់។

កៈ បាទម៉ាក់យាយបាទ ចុះសំរាប់ម៉ាក់យាយមានអីចង់ផ្តែផ្តាំអីផ្សេងទៀតទេម៉ាក់យាយ?

ខៈ មានតែប៉ុណ្ណឹងទេមិនដឹងថាផ្តែផ្តាំយ៉ាងម៉េចទៀតទេនឹង។

កៈ ចុះបើសិនជាចង់អោយជៀសវៀងវិញ
តើម៉ាក់យាយចង់អោយពួកគាត់ជៀសវៀងពីអីគេដែរម៉ាក់យាយ?

ខៈ អូ៎!!ជៀសវៀងដូចថាខាងគ្រឿងញៀនអីចឹងទៅណាស់
យើងប្រាប់កូនចៅកុំអោយវាមានប៉ះពាល់ចឹង ទៅណាស់។

កៈ បាទម៉ាក់យាយ?

ខៈ យើងមិនដឹងថាគេស្តាប់រឺមួយមិនស្តាប់យើងមិនដឹងដែរនឹង។

កៈ ប៉ុន្តែយើងនឹង?

ខៈ យើងចេះតែណែនាំកូនទៅ។

កៈ
ប៉ុន្តែយើងនឹងតំកល់ទុកនូវប្រវត្តិមួយនេះមីងដើម្បីអោយមីងអាចដឹងពីប្រវត្តិរបស់មីងហាស
?

ខៈ ចា៎!!នឹងហើយ។

កៈ បាទចឹងជាចុងក្រោយខ្ញុំអរគុណមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង
ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលា។

ខៈ ចា៎!!នឹងហើយ។

កៈ ដើម្បីតំកល់ទុកអោយមីង បាទចឹងអរគុណច្រើនណាស់មីង៕៕៕